## ២-សេចក្តីសំរេច

រាជធានីភ្នំពេញ , ថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០០០

**សេចក្តីសំរេចលេខ ៨០ សសរ**

**ស្តីពីការ បើកថ្នាក់បរិញ្ញាប័ត្រវិទ្យាសាស្ត្រកសិកម្ម**

**តាមរូបភាពបង់ថ្លៃសិក្សា នៅសាកលវិទ្យាល័យភូមិន្ទកសិកម្ម**

****

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨ ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ /នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ ១១៥ អនក្រ.បក ចុះថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ ១៩៩៩ ស្តីពីការបង្កើតសាកលវិទ្យាល័យភូមិន្ទកសិកម្ម ជាគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី ៧ ខែ មេសា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- តាមសំណើរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

**សំរេច**

**ប្រការ ១ :** អនុញ្ញាតឲ្យសាកលវិទ្យាល័យភូមិន្ទកសិកម្ម បើកថ្នាក់បរិញ្ញាប័ត្រវិទ្យាសាស្ត្រកសិកម្ម សិក្សាបង់ថ្លៃ ចាប់ពីឆ្នាំសិក្សា ២០០០-២០០១ នេះតទៅ ។

**ប្រការ ២ :** អាចចូលសិក្សាថ្នាក់បរិញ្ញាប័ត្រវិទ្យាសាស្ត្រកសិកម្មបាន ជនគ្រប់រូបដែលមានសញ្ញាប័ត្រដូចខាងក្រោម :

-សំរាប់បរិញ្ញាប័ត្រថ្នាក់បាសីលីយ៉េ :

-សញ្ញាប័ត្រមធ្យមសិក្សាទុតិយភូមិ ឬសញ្ញាប័ត្រមានតំលៃស្មើ

-សញ្ញាប័ត្រមធ្យមសិក្សាកសិកម្មកំរិត ២

-សំរាប់បរិញ្ញាប័ត្រថ្នាក់ម៉ាស្ទ័រ : បរិញ្ញាប័ត្រថ្នាក់បាសីលីយ៉េ ឬសញ្ញាប័ត្រមានតំលៃស្មើ

ប្រការ ៣ : របៀបសិក្សា :

-ថ្នាក់បាសឺលើរ អនុវត្តកម្មវិធីសិក្សារយៈពេល ៤ ឆ្នាំ និង ៦ ខែ ត្រូវជា ១៦៨ ក្រេឌីត តាមនិយាមថ្នាក់បរិញ្ញាប័ត្រនិតិសាមញ្ញ

-ថ្នាក់ម៉ាស្ទ័រ អនុវត្តកម្មវិធីសិក្សារយៈពេល ២ ឆ្នាំ ត្រូវជា ៥៥ ក្រេឌីត ជាអប្បរមា

-កម្មវិធីសិក្សាទទួលស្គាល់ដោយក្រសួងអប់រំ យុវជន និងកីឡា

-សិក្សារួមផ្សំទាំងប្រព័ន្ធសិក្សាបង់ថ្លៃ និង ប្រព័ន្ធសិក្សានិតិសាមញ្ញ

-បរិញ្ញាប័ត្រសិក្សាបង់ថ្លៃ និង បរិញ្ញាប័ត្រនិតិសាមញ្ញមានតំលៃស្មើគ្នា

-សាកលវិទ្យាល័យភូមិន្ទកសិកម្ម ជាអ្នកចេញបរិញ្ញាប័ត្រ ដែលមានការទទួលស្គាល់ពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

ប្រការ ៤ : ក្រុមប្រឹក្សាភិបាលរបស់សាកលវិទ្យាល័យ ត្រូវកំណត់លក្ខខណ្ឌសិក្សាលំអិត កំណត់តំលៃសិក្សាសមស្រប និង អាចបង្កើតឧបសម្ព័ន្ធសិក្សាបង់ថ្លៃនៅតាមបណ្តាខេត្តនានា ។

ប្រការ ៥ : បទប្បញ្ញត្តិដែលមានខ្លឹមសារផ្ទុយ ពីសេចក្តីសំរេចនេះ ត្រូវទុកជានិរាករណ៍ ។

ប្រការ ៦ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួង អប់រំយុវជន និងកីឡា រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រី រដ្ឋលេខាធិការនៃក្រសួង រដ្ឋលេខាធិការដ្ឋានពាក់ព័ន្ធ និងសាកលវិទ្យាល័យភូមិន្ទកសិកម្ម ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសំរេចនេះ តាមភារកិច្ចរៀងៗខ្លួន ។

ប្រការ ៧ : សេចក្តីសំរេចនេះចូលជាធរមាន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ហ៊ុន សែន

★★★

រាជធានីភ្នំពេញ, ថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០០០

## សេចក្តីសំរេចលេខ ៤១ សសរ

## ស្តីពីការបង្កើតគណៈកម្មការជាតិកែទម្រង់ការគ្រប់គ្រងអាវុធជាតិផ្ទុះ នៅកម្ពុជា

****

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨ /៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា